ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៧០៩ សហវ.ប្រក

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការប្រគល់នីតិសម្បទាជាគណនេយ្យករគយ ជូនមន្ត្រីរាជការគយនិងរដ្ឋាករ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋាន ពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពី ការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពី បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ប្រគល់នីតិសម្បទាជាគណនេយ្យករគយ ជូនមន្ត្រីរាជការគយនិងរដ្ឋាករចំនួន ១២០ រូប ដូចមានរាយនាមក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២.-**

គណនេយ្យករគយមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- អនុវត្តកិច្ចប្រតិបត្តិការគណនេយ្យ និងរដ្ឋបាល តាមបណ្តាអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធនានា តាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា រាប់បញ្ចូលទាំងការចូលរួមធ្វើផែនការប្រើប្រាស់ឯកសារបោះពុម្ព និងផែនការចំណូល ចំណាយផ្សេងៗ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។
- គ្រប់គ្រង ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លើការងារប្រមូលចំណូលពន្ធ អាករ ប្រាក់ពិន័យ និងកម្រៃគយ ព្រមទាំងនិមុត្តិធានាគ្រប់ប្រភេទ តាមបទប្បញ្ញត្តិជាធរមាន រាប់បញ្ចូលទាំងការងារផ្ទៀងផ្ទាត់កាតព្វកិច្ចពន្ធ-អាករ សរសេរបង្កាន់ដៃ ការគ្រប់គ្រងប្រាក់ចំណូល និងបញ្ជិកាគណនេយ្យគ្រប់ប្រភេទ ផងដែរ ។
- គ្រប់គ្រងការងារបង់ចំណូលគ្រប់ប្រភេទចូលថវិការដ្ឋឲ្យបានទាន់ពេលវេលាកំណត់ និងមានភារកិច្ចផ្ទៀងផ្ទាត់សលាកប័ត្របង់ប្រាក់ចំណូលគយនានា ជាមួយរតនាគាររៀងរាល់ដំណាច់ខែនីមួយៗ ព្រមទាំងទទួលបន្ទុកគ្រប់គ្រងការចំណាយមានការអនុញ្ញាតផ្សេងៗ របស់អង្គភាពគយពាក់ព័ន្ធផងដែរ ។
- គ្រប់គ្រង ថែរក្សា និងត្រួតពិនិត្យឯកសារគណនេយ្យ និងឯកសារពាក់ព័ន្ធគ្រប់ប្រភេទ ដែលបម្រើឲ្យការងារប្រមូលចំណូលគយ ។
- គ្រប់គ្រងទំនិញដែលស្ថិតក្នុងសន្និធិ និង/ឬ ភណ្ឌាគារគយនានា តាមបទប្បញ្ញត្តិជាធរមាន ។
- ទទួលបន្ទុកគ្រប់គ្រងធ្វើរបាយការណ៍ ព្រមទាំងបូកសរុបការងារគណនេយ្យ រដ្ឋបាល និងស្ថិតិ ឲ្យបានទៀងទាត់ តាមទម្រង់កំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៣.-**

គណនេយ្យករគយមានសិទ្ធិ ដូចខាងក្រោម ៖

- ទំនាក់ទំនង សហការជាមួយបណ្តាអង្គភាពគយ ឬបុគ្គលពាក់ព័ន្ធ ដើម្បីស្រាវជ្រាវ និងប្រមូលឯកសារនានា សម្រាប់តម្រូវការនៃការបំពេញភារកិច្ចរបស់ខ្លួន ។
- រាយការណ៍ដោយផ្ទាល់មកការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ នៃនាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង និងមកការិយាល័យសវនកម្មផ្ទៃក្នុង នៃលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានគយនិង

រដ្ឋាករកម្ពុជា ក្នុងករណីជួបប្រទះនូវឧបសគ្គនានាក្នុងការអនុវត្តតួនាទី និងសិទ្ធិរបស់ខ្លួន ផ្សេងទៀត តាមបទប្បញ្ញត្តិជាធរមាន ។

- ចូលរួមក្រុមត្រួតពិនិត្យឯកសារ ឬក្រុមត្រួតពិនិត្យរូបវន្តលើទំនិញនានា ក្នុងករណីយល់ថាចាំបាច់ ដើម្បីផ្ទៀងផ្ទាត់រកភាពមិនប្រក្រតី ឬសំណូមពរផ្សេងទៀត ជាយថាហេតុ ។

**ប្រការ ៤.-**

គណនេយ្យករគយ ត្រូវអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិរបស់ខ្លួន តាមការចាត់តាំងប្រគល់ភារកិច្ច និងតាមទីកន្លែងដែលកំណត់ដោយអគ្គនាយកគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.............................. សហវ.......

## បញ្ជីរាយនាមមន្ត្រីរាជការគយនិងរដ្ឋាករ ដែលត្រូវទទួលនីតិសម្បទាជាគណនេយ្យករគយ

(ឧបសម្ព័ន្ធប្រកាសលេខ ៧០៩ សហវ.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

| លេខរៀង | គោត្តនាមនិងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | អត្តលេខ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 1 | កាឌុល កាន់ដារិទ្ធ | ប្រុស | 17-11-1980 | 1358 | |
| 2 | ភឿកជ្រុន ច័ន្ទរិទ្ធិ | ប្រុស | 31-08-1981 | 1298 | |
| 3 | ក្រេង សុខគីម | ប្រុស | 10-09-1982 | 1297 | |
| 4 | កែវ អង្គាម | ប្រុស | 15-02-1979 | 1344 | |
| 5 | កែវ គីមឃន | ប្រុស | 01-11-1975 | 1392 | |
| 6 | កៅ ម៉ៅ | ប្រុស | 17-02-1980 | 1372 | |
| 7 | កោះ និច្ច | ប្រុស | 26-01-1974 | 1289 | |
| 8 | ខណ្ណារ៉ា អេលីត | ប្រុស | 24-03-1983 | 1383 | |
| 9 | ខូវ គីអាន | ប្រុស | 04-11-1984 | 1360 | |
| 10 | ខេង សាំងឡេង | ប្រុស | 04-06-1973 | 1393 | |
| 11 | គីម ណាលី | ស្រី | 15-10-1983 | 1308 | |
| 12 | គីម ឆាត | ប្រុស | 27-12-1977 | 1325 | |
| 13 | គីម សីលា | ប្រុស | 06-01-1984 | 1398 | |
| 14 | គួន សំណាង | ប្រុស | 25-07-1982 | 1387 | |
| 15 | ងួន ផាន់ណា | ប្រុស | 01-08-1981 | 1379 | |
| 16 | ង៉ែត សម្បត្តិ | ប្រុស | 21-12-1978 | 1322 | |
| 17 | ចាប ស៊ុនថារិទ្ធ | ប្រុស | 01-09-1981 | 1304 | |
| 18 | ចេង ឈុន | ប្រុស | 01-12-1976 | 1348 | |
| 19 | ជន់ រចនា | ប្រុស | 10-05-1981 | 1318 | |
| 20 | ជ័យ ពិសិដ្ឋ | ប្រុស | 22-01-1984 | 1377 | |
| 21 | ជ័យ សុខជា | ប្រុស | 15-06-1982 | 1381 | |
| 22 | ជា សំណាង | ប្រុស | 05-10-1980 | 1309 | |
| 23 | ជាស័ក្តិ ថារី | ស្រី | 08-03-1977 | 1314 | |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

| | | | | | |
|---|---|---|---|---|---|
| 24 | ជា សំអុន | ប្រុស | 04-01-1979 | 1332 | |
| 25 | ជាវ ចាន់ធូ | ប្រុស | 21-02-1979 | 1391 | |
| 26 | ជ្រិន សំអាត | ប្រុស | 16-08-1974 | 1333 | |
| 27 | ឈិន សុភក្តិ | ប្រុស | 02-01-1982 | 1317 | |
| 28 | ឈុន អង្គារដ្ឋា | ប្រុស | 02-03-1980 | 1354 | |
| 29 | ឈុំ សុភា | ប្រុស | 11-11-1978 | 1326 | |
| 30 | ឈុំ សុវណ្ណ | ប្រុស | 09-10-1980 | 1403 | |
| 31 | ញឹម ដាលុច | ប្រុស | 26-03-1979 | 1328 | |
| 32 | ញ៉ែម ពុធថុនា | ប្រុស | 13-06-1980 | 1362 | |
| 33 | ញ៉ែម សុមេធ | ប្រុស | 02-02-1977 | 1386 | |
| 34 | ណុប អមរិទ្ធ | ប្រុស | 27-02-1980 | 1374 | |
| 35 | ណាំ សុលាង | ប្រុស | 01-06-1976 | 1310 | |
| 36 | ទន់ ពុទ្ធីមាន | ស្រី | 02-04-1982 | 1373 | |
| 37 | ទិត សំរេច | ប្រុស | 10-05-1975 | 1366 | |
| 38 | ទិ ច័ន្ទទីតា | ស្រី | 20-01-1981 | 1376 | |
| 39 | ទិត្យ កាល្លីណា | ប្រុស | 28-04-1981 | 1401 | |
| 40 | ទូច ស៊ីសុវណ្ណ | ប្រុស | 19-11-1983 | 1357 | |
| 41 | ទុំ មុនីរ័ត្ន | ប្រុស | 26-04-1972 | 1302 | |
| 42 | ទុំ សារិទ្ធិដា | ស្រី | 05-10-1979 | 1349 | |
| 43 | នាង រិទ្ធ | ប្រុស | 18-05-1973 | 1313 | |
| 44 | នាង សុវត្ថារ៉ា | ប្រុស | 08-09-1980 | 1407 | |
| 45 | នួន ចាន់វ៉ាន់ដា | ប្រុស | 0808-1973 | 1299 | |
| 46 | ប៉ាង ពិសិដ្ឋ | ប្រុស | 25-05-1982 | 1371 | |
| 47 | ប៉ុល សេរីបុត្រ | ប្រុស | 07-05-1981 | 1365 | |
| 48 | ប៉ែន ច័ន្ទសង្វាត | ស្រី | 19-04-1982 | 1334 | |
| 49 | ប៊ិន ដា | ប្រុស | 02-06-1974 | 1400 | |
| 50 | ប៊ុន្ទី សុជាតា | ស្រី | 02-03-1983 | 1327 | |
| 51 | ប៊ូ សុធារិទ្ធ | ប្រុស | 30-08-1982 | 1295 | |
| 52 | ប៊ូរ វង្សសំណាង | ប្រុស | 13-09-1979 | 1305 | |
| 53 | ផាត់ សុផល | ប្រុស | 05-01-1980 | 1339 | |
| 54 | ផាន់ ម៉េងហ៊ាង | ប្រុស | 28-07-1978 | 1351 | |
| 55 | ផេង សុខ | ប្រុស | 10-07-1976 | 1340 | |
| 56 | ផេង ប៊ុនថន | ប្រុស | 15-05-1973 | 1394 | |
| 57 | ពិត សារិត | ប្រុស | 07-06-1974 | 1405 | |

| | | | | | |
|---|---|---|---|---|---|
| 58 | ពេជ លីណា | ប្រុស | 20-07-1981 | 1390 | |
| 59 | ពេជ វ៉ាន់ធី | ប្រុស | 10-10-1975 | 1395 | |
| 60 | ព្រំ សីហា | ប្រុស | 16-08-1981 | 1294 | |
| 61 | ព្រំ លឹម | ប្រុស | 07-12-1977 | 1320 | |
| 62 | មន្ត ម៉ីរីយ៉ា | ប្រុស | 23-03-1983 | 1338 | |
| 63 | មាស សំអាង | ប្រុស | 23-09-1982 | 1292 | |
| 64 | ម៉ឹម ម៉ុន | ប្រុស | 11-10-1979 | 1350 | |
| 65 | មុយ បញ្ញារិទ្ធ | ប្រុស | 01-09-1978 | 1384 | |
| 66 | ម៉ាក់ វិសាល | ប្រុស | 02-12-1980 | 1311 | |
| 67 | ម៉េង ផល្លុន | ប្រុស | 17-04-1979 | 1368 | |
| 68 | ម៉ែន ស៊ីថា | ប្រុស | 06-10-1978 | 1347 | |
| 69 | ម៉ៅ ភិរម្យ | ប្រុស | 24-08-1982 | 1361 | |
| 70 | ម៉ៅ ណារ៉ា | ប្រុស | 10-08-1981 | 1406 | |
| 71 | យ៉េន ដាណែត | ស្រី | 06-06-1982 | 1375 | |
| 72 | យ៉ែម ប៊ុនថា | ប្រុស | 07-01-1975 | 1355 | |
| 73 | រិត រ័ត្នគីរី | ស្រី | 10-01-1981 | 1346 | |
| 74 | រ៉ង រដ្ឋា | ប្រុស | 13-04-1981 | 1389 | |
| 75 | លន ចិត្រា | ប្រុស | 01-11-1973 | 1307 | |
| 76 | លី ម៉េងឃាង | ប្រុស | 03-08-1976 | 1288 | |
| 77 | លី ស៊ីដេន | ប្រុស | 28-10-1980 | 1306 | |
| 78 | វៃន ម៉ៅ | ប្រុស | 27-11-1972 | 1397 | |
| 79 | វ៉ាន់ បូរិន | ប្រុស | 08-08-1979 | 1353 | |
| 80 | សរ វិចិត្រ | ប្រុស | 30-06-1981 | 1324 | |
| 81 | ស សារ៉ាត់ | ប្រុស | 25-08-1981 | 1359 | |
| 82 | សាផុន សុផាណ្ណារិន | ប្រុស | 15-11-1981 | 1343 | |
| 83 | សុខ ចំណាន | ប្រុស | 23-12-1981 | 1300 | |
| 84 | សុខ រតនា | ប្រុស | 22-07-1981 | 1323 | |
| 85 | សុខ សុធីរៈ | ប្រុស | 25-07-1982 | 1363 | |
| 86 | សឿ សោភ័ណ | ប្រុស | 24-06-1983 | 1336 | |
| 87 | សេង សុបញ្ញា | ប្រុស | 04-01-1980 | 1378 | |
| 88 | សេង ម៉េងស្រ៊ាន់ | ប្រុស | 18-10-1980 | 1388 | |
| 89 | សំអុន សំរេច | ប្រុស | 19-06-1983 | 1321 | |
| 90 | សំ វុទ្ធី | ប្រុស | 07-05-1980 | 1380 | |
| 91 | សាំង សុខា | ប្រុស | 06-10-1980 | 1341 | |

| | | | | | |
|---|---|---|---|---|---|
| 92 | ស៊ាន វឌ្ឍា | ប្រុស | 24-12-1981 | 1290 | |
| 93 | ស្រួយ ព្រើត | ប្រុស | 10-02-1979 | 1303 | |
| 94 | ហម នី | ប្រុស | 16-05-1974 | 1385 | |
| 95 | ហុក កុម្ភៈ | ប្រុស | 02-02-1979 | 1301 | |
| 96 | ហុង បូណា | ប្រុស | 07-05-1980 | 1402 | |
| 97 | ហូ សុភក្ត្រា | ប្រុស | 01-09-1980 | 1342 | |
| 98 | ហូ ស្រស់វរលក្ខណ៍ | ប្រុស | 15-05-1977 | 1364 | |
| 99 | ហួង ធីតា | ប្រុស | 23-08-1979 | 1287 | |
| 100 | ហួង រតនា | ប្រុស | 18-09-1981 | 1315 | |
| 101 | ហួយ សុខា | ស្រី | 17-08-1980 | 1396 | |
| 102 | ហេង យូស៊ា | ប្រុស | 06-01-1979 | 1319 | |
| 103 | ហេង មករា | ប្រុស | 05-01-1976 | 1367 | |
| 104 | ហេង សុភា | ប្រុស | 06-08-1977 | 1408 | |
| 105 | ហែម សុភ័ក្ត្រ | ប្រុស | 02-10-1980 | 1356 | |
| 106 | ហោ ស៊ីណាត | ប្រុស | 19-04-1982 | 1331 | |
| 107 | ហ៊ិន បូរ៉ា | ប្រុស | 30-07-1970 | 1335 | |
| 108 | ហ៊ាន វណ្ណៈ | ប្រុស | 23-04-1980 | 1330 | |
| 109 | ឡា វិសិដ្ឋ | ប្រុស | 13-02-1980 | 1399 | |
| 110 | ឡាយ ឆវីនឌីម៉ា | ប្រុស | 03-12-1983 | 1345 | |
| 111 | អាត អឿន | ប្រុស | 27-07-1974 | 1329 | |
| 112 | អោម សុភៈ | ប្រុស | 18-07-1973 | 1337 | |
| 113 | អ៊ាង ស៊ីម | ប្រុស | 29-11-1974 | 1369 | |
| 114 | អ៊ី ណារិទ្ធ | ប្រុស | 18-04-1980 | 1370 | |
| 115 | អ៊ុយ សាវីណែត | ស្រី | 07-02-1982 | 1291 | |
| 116 | អ៊ុក គីមសៀ | ប្រុស | 15-07-1978 | 1293 | |
| 117 | អ៊ុច ចំណាន | ប្រុស | 19-12-1980 | 1296 | |
| 118 | អ៊ុន ហោម៉ាលីន | ប្រុស | 29-07-1974 | 1312 | |
| 119 | អ៊ុក សូរិយា | ស្រី | 25-08-1983 | 1352 | |
| 120 | អ៊ុក វណ្ណឫទ្ធិ | ប្រុស | 31-10-1979 | 1382 | |

បានបញ្ឈប់បញ្ជីត្រឹមលេខរៀងទី ១២០ ( មួយរយម្ភៃ) ។